ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....៩១៦....សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតការិយាល័យសម្ភារៈ និង ទ្រព្យសម្បត្តិរដ្ឋ នៃនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦០១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- តាមតម្រូវការការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតការិយាល័យសម្ភារៈ និង ទ្រព្យសម្បត្តិរដ្ឋស្ថិតនៅក្រោមនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ២ :** ការិយាល័យសម្ភារៈ និង ទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣ :** ការិយាល័យសម្ភារៈ និង ទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោម ÷

- ប្រមូលផ្តុំតម្រូវការនៃការប្រើប្រាស់ គ្រប់គ្រង និងបែងចែកសម្ភារៈ បរិក្ខារ និងប្រេងឥន្ធនៈ សម្រាប់បម្រើសេចក្តីត្រូវការរបស់ក្រសួង និង បណ្តាអង្គភាពក្រោមឱវាទ
- គ្រប់គ្រង ថែទាំ ពិនិត្យផ្តល់យោបល់លើសំណើសុំជួសជុលយានយន្តរបស់រដ្ឋ
- កត់ត្រា ចងក្រង និង គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង និង បណ្តាអង្គភាពក្រោមឱវាទ ដែលរួមមានចលនទ្រព្យ និង អចលនទ្រព្យ
- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ប្រចាំឆ្នាំ នូវបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង និង បណ្តាអង្គភាពក្រោមឱវាទ
- ផ្តល់យោបល់ ទទួលគ្រប់គ្រងដីធ្លី គ្រឿងម៉ាស៊ីន គ្រឿងសង្ហារឹម សម្ភារៈ បរិក្ខារ ប្រេងឥន្ធនៈ យានយន្ត និង សំណង់សាងសង់ថ្មី
- លើកសំណើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នូវចលនទ្រព្យ និង អចលនទ្រព្យ ដែលមិនប្រើប្រាស់ ឬ ប្រើប្រាស់លែងកើត
- ជំរុញការធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីរបស់រដ្ឋ ដែលគ្រប់គ្រងដោយក្រសួង និង បណ្តាអង្គភាពក្រោមឱវាទ
- ចូលរួមដោះស្រាយរាល់វិវាទកម្មផ្សេងៗ ដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ក្រសួង និង បណ្តាអង្គភាពក្រោមឱវាទ ដើម្បីទប់ស្កាត់រាល់បាតុភាពរំលោភបំពានយកទ្រព្យសម្បត្តិរដ្ឋ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

**គាត ឈន់**

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  «ដើម្បីជូនជ្រាប»
- ដូចប្រការ ៥
- ឯកសារ- កាលប្បវត្តិ